**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៤ អនក្រ-បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សាកលវិទ្យាល័យវេស្ទើន

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពី ការបង្កើត ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក. ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ. ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពី ការបង្កើត និង ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០០២ ស្តីពី លក្ខណៈវិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញលិខិតស្នើសុំ របស់លោក តែ ឡឺរិន ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៣
- បានឃើញយោបល់ របស់ក្រសួងអប់រំ យុវជន និង កីឡា

## សម្រេច

**មាត្រា ១ :** ទទួលស្គាល់ គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា " **សាកលវិទ្យាល័យ វេស្ទើន** "

" WESTERN UNIVERSITY " ហៅកាត់ជាភាសាខ្មែរ "ស.វ." និង ហៅជាភាសាអង់គ្លេស " WU " ។ សាកលវិទ្យាល័យនេះ មានទីតាំងគោល ស្ថិតនៅ អាគារលេខ ១៥ ផ្លូវលេខ ៥២៨ សង្កាត់ បឹងកក់ ១ ខ័ណ្ឌ ទួលគោក រាជធានីភ្នំពេញ ។

មាត្រា ២ : សាកលវិទ្យាល័យវេស្ទើន ស្ថិតនៅក្រោមឱវាទ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៣ : សាកលវិទ្យាល័យវេស្ទើន ធ្វើការបណ្តុះបណ្តាល :

- ថ្នាក់ បរិញ្ញាប័ត្ររង សិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ ។
- ថ្នាក់ បរិញ្ញាប័ត្រ សិក្សារយៈពេលយ៉ាងតិច ៤ឆ្នាំ ។
- ថ្នាក់ ម៉ាស្ទ័រ សិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ ។
- ថ្នាក់ បណ្ឌិត សិក្សាស្រាវជ្រាវ រយៈពេលយ៉ាងតិច ៣ឆ្នាំ ។

មាត្រា ៤ : សាកលវិទ្យាល័យវេស្ទើន មានមហាវិទ្យាល័យចំនួន ៤ និង មជ្ឈមណ្ឌលបណ្តុះបណ្តាលមួយៈ

- មហាវិទ្យាល័យ សិល្បៈ មនុស្សសាស្ត្រ និង ភាសា
- មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម
- មហាវិទ្យាល័យ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- មហាវិទ្យាល័យគ្រប់គ្រង និង សណ្ឋាគារ-ទេសចរណ៍
- មជ្ឈមណ្ឌល សិក្សាជំនាញ រយៈពេលខ្លី ។

ទៅអនាគត សាកលវិទ្យាល័យនេះ អាចបើកមហាវិទ្យាល័យ សាខា ឯកទេស ឬ ប្រភេទបណ្តុះ-បណ្តាល ដទៃទៀត ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាត ពីក្រសួងអប់រំ យុវជន និង កីឡា ។

មាត្រា ៥ : សាកលវិទ្យាល័យវេស្ទើន មានក្រុមប្រឹក្សាភិបាលមួយ សំរាប់ពិនិត្យ និង សំរេចលើ គោលនយោបាយ ផែនការអភិវឌ្ឍ អនុម័តលើកម្មវិធីសិក្សា និង ការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត ។

មាត្រា ៦ : ក្នុងលក្ខខណ្ឌទទួលសិស្សអោយចូលរៀន សាកលវិទ្យាល័យវេស្ទើន ត្រូវគោរពតាមបទដ្ឋានរបស់ក្រសួងអប់រំ យុវជននិងកីឡា ដែលកំនត់អំពីការជ្រើសរើសនិស្សិតអោយចូលរៀននៅតាមគ្រឹះស្ថានឧត្តមសិក្សា ។

មាត្រា ៧ : សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យវេស្ទើន មានភារកិច្ច :

- ទទួលខុសត្រូវនៅចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យ ។
- ជ្រើសរើសសិស្ស-និស្សិតអោយចូលរៀន ជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន និង បុគ្គលិកបំរើការងារ ។
- គ្រប់គ្រងអោយបានល្អ នូវការងារបណ្តុះបណ្តាល ការងារស្រាវជ្រាវ ការប្រលងនិងការប្រគល់សញ្ញាប័ត្រ ។
- គោរព និង អនុវត្តតាម សារាចរ និង សេចក្តីណែនាំ របស់រាជរដ្ឋាភិបាល ។
- ធានាអោយបាន នូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម ។
- ធ្វើរបាយការណ៍ រាល់សកម្មភាពសិក្សា ជូននាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា អោយបានទៀងទាត់ តាមការកំណត់ ។

**មាត្រា ៨ :** និស្សិត ដែលរៀនចប់កម្មវិធីសិក្សារបស់សាកលវិទ្យាល័យវេស្ទើន និង ទទួលបានជោគជ័យ ក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាប័ត្រតាមកំរិត និង តាមឯកទេសដែលបានសិក្សា ។ សញ្ញាប័ត្រនេះ ផ្តល់អោយដោយសាកលវិទ្យាល័យវេស្ទើន ហើយ ត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណី សាកលវិទ្យាល័យនេះ បំពេញ និង អនុវត្ត បានតាមគោលការណ៍ និងបទដ្ឋានកំនត់ របស់ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៩ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អគ្គនាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និងសាកលវិទ្យាល័យវេស្ទើន មានភារកិច្ចរៀង១ខ្លួន ដើម្បីអនុវត្តនិងប្រតិបត្តិតាមអនុក្រឹត្យនេះ ។

**មាត្រា ១០ :** អនុក្រឹត្យនេះ មានប្រសិទ្ធភាព គតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

ភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាក្រុងភ្នំពេញ

" <u>ដើម្បីមុខការ</u> "

- ដូចមាត្រា ៩ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ